# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧

# ឯកអគ្គរដ្ឋទូតនឹងធ្វើដំណើរទៅខេត្តព្រះសីហនុ

ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា លោកជំទាវ **អេនជេលឡា ខកខឺរ៉េន** នឹងធ្វើដំណើរជាផ្លូវការទៅកាន់ខេត្តព្រះសីហនុនាសប្តាហ៍នេះ ។

ដំណើរទស្សនកិច្ចនេះនឹងផ្តោតលើកិច្ចសហប្រតិបត្តិការរវាងអូស្ត្រាលីនិងកម្ពុជា ក្នុងការដោះស្រាយរួមគ្នានូវបញ្ហាប្រឈមផ្នែកសន្តិសុខព្រំដែននិងលម្ហរសមុទ្រក្នុងតំបន់ឥណ្ឌូប៉ាស៊ីភិច។

លោកជំទាវខកខឺរ៉េន នឹងធ្វើដំណើរទៅកាន់មូលដ្ឋានទ័ពជើងទឹកសមុទ្ររាម ដែលនៅទីនោះ លោកជំទាវនឹងជួបប្រជុំជាមួយមេបញ្ជាការមូលដ្ឋានសមុទ្ររាម  ឯកឧត្តមឧត្តមនាវីឯក **អ៊ុក សីហា** និងមេបញ្ជាការនៃបញ្ជាការដ្ឋានជួរមុខនៃអគ្គលេខាធិការដ្ឋានគណៈកម្មការជាតិសន្តិសុខលម្ហរសមុទ្រ ឯកឧត្តមឧត្តមនាវីឯក **ទា សុខា**។

ឯកអគ្គរដ្ឋទូតនឹងពិនិត្យគ្រឿងបរិក្ខានិងកម្មវិធីបណ្តុះបណ្តាលនៅមូលដ្ឋានសមុទ្ររាមក្រោមការគាំទ្រដោយកម្មវិធីកិច្ចសហប្រតិបត្តិការយោធាអូស្ត្រាលី។

នៅថ្ងៃសុក្រ ទី១៩ ខែឧសភា ឯកអគ្គរដ្ឋទូតនឹងចូលរួមបើកសម្ពោធនូវអង្គភាពត្រួតពិនិត្យកុងតឺន័រនៃកំពង់ផែព្រះសីហនុ។ រដ្ឋាភិបាលអូស្ត្រាលី និងកាណាដា បានចូលរួមឧបត្ថម្ភដល់ការរៀបចំនូវអង្គភាពត្រួតពិនិត្យកុងតឺន័រនេះ តាមរយៈការិយាល័យអង្គការសហប្រជាជាតិសម្រាប់គ្រឿងញៀន និងឧក្រិដ្ឋកម្ម និងកម្មវិធីត្រួតពិនិត្យកុងតឺន័ររបស់អង្គការគយពិភពលោក។

គ្រឿងបរិក្ខានិងវគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងតាមរយៈកម្មវិធីត្រួតពិនិត្យកុងតឺន័រនេះ នឹងជួយសម្រួលដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់បន្ថយឧប្បត្តិហេតុនៃបទល្មើសឆ្លងដែននិងដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងនូវសន្តិសុខព្រំដែននៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីភិច។

ខណៈលោកជំទាវនៅខេត្តព្រះសីហនុ លោកជំទាវឯកអគ្គរដ្ឋទូតខកខឺរ៉េន ក៏នឹងជួបជាមួយអ្នកពាក់ព័ន្ធក្នុងដំណើរការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ ដើម្បីស្តាប់អំពីការត្រៀមរៀបចំមុនពេលថ្ងៃបោះឆ្នោតទី៤ ខែមិថុនា ។

ទំនាក់ទំនងព័ត៌មាន៖ Australian.Embassy.Cambodia@dfat.gov.au

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413